ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល
លេខៈ ០៤៧/២៣ អអរ

## សេចក្តីប្រកាសព័ត៌មាន
## លទ្ធផលនៃសន្និសីទសារព័ត៌មានស្តីពី "ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តតាកែវ"

នាព្រឹកថ្ងៃទី០២ ខែមីនា ឆ្នាំ២០២៣ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី **«ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តតាកែវ»** ដែលមានវាគ្មិនចូលរួមគឺៈ

- **ឯកឧត្តម អ៊ូច ភា អភិបាលនៃគណៈអភិបាលខេត្តតាកែវ**
- **មន្ទីរអង្គភាពជំនាញជុំវិញរដ្ឋបាលខេត្តតាកែវ**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងពន្យល់ និងផ្សព្វផ្សាយដល់សាធារណជនឱ្យបានជ្រាបច្បាស់អំពី យន្តការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងភាពជោគជ័យដែលរដ្ឋបាលខេត្តតាកែវ ខិតខំប្រឹងប្រែងអនុវត្ត ព្រមទាំងសម្រេចបានសមិទ្ធផលវិជ្ជមាន ក្រោមការដឹកនាំដ៏ប៉ិនប្រសប់ប្រកបដោយថាមពលរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

## I. ស្ថានភាពទូទៅ

ខេត្តតាកែវ មានផ្ទៃដីសរុប ៣.៦៨០,១៥គីឡូម៉ែត្រការ៉េ បែងចែកចេញជា ១០ក្រុង-ស្រុក ១០០ឃុំ-សង្កាត់ និង១.១២១ភូមិ មានប្រជាពលរដ្ឋរស់នៅសរុបចំនួន ១.០៥៣.៩៩៧នាក់ ស្រ្តី ៥៤២.៤៧៧នាក់ ស្មើនឹង២៣៣.៨៧៧គ្រួសារ ដោយទំហំសេដ្ឋកិច្ចខេត្តទាំងមូលមានចំនួនប្រមាណ ៦.៨១២.៦៨០,៧លានរៀល ស្មើនឹង ៦,២%នៃសេដ្ឋកិច្ចជាតិ និងចំណូលជាមធ្យមសម្រាប់មនុស្សម្នាក់ៗ (GDP) មានការកើនឡើងជាលំដាប់ចាប់ពី១.៣៦៤ដុល្លារ/ម្នាក់នៅឆ្នាំ២០១៨ ទៅដល់ ១.៥២៦ដុល្លារ/ម្នាក់ នៅឆ្នាំ២០២១។

## II. សមិទ្ធផលការងារ

ក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ(២០១៨-២០២២) សមិទ្ធផលការងារសំខាន់ៗ ដែលសម្រេចបានរួមមាន៖

- **វិស័យគាំពារសង្គម៖** រដ្ឋបាលខេត្ត បានអនុវត្តនូវគោលនយោបាយគាំពារសង្គរបស់រាជរដ្ឋាភិបាល ក្នុងការដោះស្រាយជីវភាពរបស់ប្រជាពលរដ្ឋ អំឡុងពេលសង្គមជាតិប្រឈមនឹងវិបត្តិផ្សេងៗ ដោយបានអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩សរុប ៣៨.៩០១គ្រួសារ អស់ថវិកាចំនួន ១៩៤.៣៧៦.៥៩៦.០០០រៀល, ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំសរុបចំនួន ៧.៦៨១នាក់ មានទឹកប្រាក់ សរុបចំនួន ៣.៣១៧.៨០០.០០០រៀល, គ្រួសារងាយរងហានិភ័យ ក្នុងអំឡុងពេលមានសម្ពាធអតិផរណា សរុបចំនួន ២៦.៥៩៨គ្រួសារ មានទឹកប្រាក់ សរុបចំនួន ៣.៥៥៦.១៦៨.១០០រៀល និងរងផលប៉ះពាល់ធ្ងន់ធ្ងរដោយគ្រោះទឹកជំនន់សរុប ៤.៧២០គ្រួសារ មានទឹកប្រាក់ សរុបចំនួន ៧៤៦.០៨០.០០០រៀល។ ជាមួយគ្នានេះ រដ្ឋបាលខេត្ត បានសាងសង់លំនៅឋានជូនគ្រួសារអតីតយុទ្ធជន ពលី ពិការ និងគ្រួសារនិវត្តជន ដែលជាគោលនយោបាយរបស់រាជរដ្ឋាភិបាល បានចំនួន ៦៣ខ្នង។
- **វិស័យកសិកម្ម៖** ជាខេត្តដែលអំណោយផលពីធម្មជាតិ អាកាសធាតុ សណ្ឋានដី ដីជីវជាតិ និងប្រព័ន្ធស្រោចស្រពគ្រប់គ្រាន់ ធ្វើឱ្យខេត្តតាកែវជាប់ជាខេត្តជង្រុកស្រូវទី២ នៃព្រះរាជាណាចក្រកម្ពុជា ដោយទូទាំងខេត្តទាំងមូលធានាបាននូវសន្តិសុខស្បៀង និងបាននាំចេញទៅក្រៅប្រទេស ព្រមទាំងផ្គត់ផ្គង់ទូទាំងប្រទេសផងដែរ។ ខេត្តមានផ្ទៃបង្កបង្កើនផលស្រូវសរុប ១.៥៦៩.២៨៦ ហិកតា ទទួលបានបរិមាណផលសរុបចំនួន ៦.១៤៧.២៩៦ តោន និងបរិមាណស្រូវនៅសល់សម្រាប់ធ្វើការ នាំចេញទៅរាជធានីភ្នំពេញ និងប្រទេសវៀតណាមតាមច្រកព្រំដែនសរុបចំនួន ៤.១៤១.២៣៣តោន។ ផ្ទៃដីដំណាំរួមផ្សំចំនួន ៤.០០០ហិកតា ជាមួយគ្នានេះ ប្រព័ន្ធធារាសាស្ត្រសម្រាប់ទ្រទ្រង់ការងារកសិកម្មសរុបចំនួន ១៣០ប្រព័ន្ធ។ ទន្ទឹមនឹងនោះ រដ្ឋបាលខេត្ត ក៏បានខិតខំអប់រំ បណ្តុះបណ្តាលជាប្រចាំ ទាំងបច្ចេកទេសដាំដុះ ការជ្រើសរើសពូជ ការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត ក្នុងន័យពង្រឹង និងបង្កើនទិន្នផល កាត់បន្ថយហានិភ័យដែលប៉ះពាល់ទៅលើសុខភាពជាចម្បង ព្រមទាំងបានជំរុញចលនាចិញ្ចឹមសត្វនៅតាមសហគមន៍ និងតាមខ្នងផ្ទះរបស់ប្រជាពលរដ្ឋ ជាពិសេសចំពោះបង្កង និងពងទាកូន ដែលជាផលិតផលសក្តានុពលរបស់ខេត្តចូលរួមចំណែកលើកកម្ពស់សេដ្ឋកិច្ចប្រជាពលរដ្ឋមូលដ្ឋាន។

- **វិស័យទេសចរណ៍៖** ខេត្តសម្បូរកោតផលធម្មជាតិ ទីតាំងប្រវត្តសាស្ត្រ វប្បធម៌ និងរមណីយដ្ឋានជាច្រើន ក្នុងនោះ រមណីយដ្ឋាទេសចរណ៍ ១០កន្លែង រមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រ ០៥កន្លែង រមណីយដ្ឋានធម្មជាតិចំនួន ០១កន្លែង រមណីយដ្ឋានវប្បធម៌ធម្មជាតិ០២កន្លែង រមណីយដ្ឋានកែច្នៃ ០២កន្លែង និងប្រាសាទបុរាណចំនួន ៣៦ប្រាសាទ ដោយទទួលបានភ្ញៀវទេសចរសរុប ៣.៥៦១.៩០៥នាក់ ក្នុងនោះ ភ្ញៀវជាតិចំនួន ៣.៥២៣.៧២០នាក់ និងភ្ញៀវអន្តរជាតិចំនួន ៣៨.១៨៥នាក់។
- **ការផ្តល់សេវាសាធារណៈ៖** តាមរយៈការអនុវត្តនូវកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្នុងន័យបង្កិតសេវាឱ្យកៀកនឹងប្រជាពលរដ្ឋ រដ្ឋបាលខេត្តបានជំរុញការផ្តល់សេវាសាធារណៈតាមរយៈអង្គភាព និងការិយាល័យច្រកចេញចូលតែមួយថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ-សង្កាត់ នៅទូទាំងខេត្ត ដោយក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ បានអនុវត្តការធ្វើប្រតិភូកម្មមុខងារចំនួន ១៤វិស័យ ដោយបានផ្តល់សេវាជូនប្រជាពលរដ្ឋចំនួន ១២៥.១៦៧នាក់ ទទួលបានចំណូលសរុប ១៥.៦៤៥.០០៨.៩៦៩រៀល។
- **ការងារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត៖** រដ្ឋបាលខេត្ត បានខិតខំបន្តជំរុញការកសាង ស្តារ និងជួសជុលជាបន្តបន្ទាប់ ទៅលើការងារហេដ្ឋារចនាសម្ព័ន្ធគ្រប់ប្រភេទ ជាពិសេសផ្លូវថ្នល់ បណ្តាញទឹកស្អាត អគ្គិសនី ប្រព័ន្ធធារាសាស្ត្រជាដើម។ ជាក់ស្តែង បច្ចុប្បន្ននេះ ទូទាំងខេត្តមានផ្លូវជាតិ និងផ្លូវខេត្តសរុប ៤១ខ្សែ មានប្រវែងសរុប ៧២២,៤៧គីឡូម៉ែត្រ ទន្ទឹមនឹងនោះ ផ្លូវជនបទមានចំនួន ២៨២ខ្សែ មានប្រវែង ៨១២,១១គីឡូម៉ែត្រ។ ជាមួយគ្នានេះ បណ្តាញផ្គត់ផ្គង់ទឹកស្អាត បានគ្របដណ្តប់ចំនួន ៥៩.០៥៩ខ្នងផ្ទះ លើ៤៦៥ភូមិ ស្មើនឹង ៤១,៥% ចំណែកអគ្គិសនី បានចែកចាយជូនប្រជាពលរដ្ឋប្រើប្រាស់ចំនួន ២២៩.៣៧៩គ្រួសារ ស្មើនឹង ៩៩,៦៤%។
- **ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ៖** ដោយមានការខិតខំប្រឹងប្រែងបំពេញការងាររបស់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់លំដាប់ថ្នាក់ទាំងអស់ ការអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវគោលនយោបាយភូមិ-ឃុំ សង្កាត់មានសុវត្ថិភាព ក្នុងខេត្តទាំងមូលរក្សាបាននូវសុខសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខសណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម បានល្អប្រសើរ បទល្មើសដែលកើតឡើងត្រូវបានបង្ក្រាបជាបន្តបន្ទាប់។ ជាមួយគ្នានេះ ខេត្តក៏បានរៀបចំផ្សព្វផ្សាយវេទិកាសាធារណៈចំនួន ១៧.៧២៩លើក ប្រជាពលរដ្ឋចូលរួមសរុបចំនួន ៧៤០.២១១នាក់ ក្នុងន័យដោះស្រាយបញ្ហាប្រឈម សំណើរ និងសំណូមពររបស់ប្រជាពលរដ្ឋ។

## III. ទិសដៅការងារបន្ត

រដ្ឋបាលខេត្ត បានដាក់ចេញនូវទិសដៅការងារសំខាន់ៗមួយចំនួន ក្នុងការបន្តអភិវឌ្ឍខេត្តទាំងមូល រួមមាន៖

- បន្តអភិវឌ្ឍន៍ទៅលើការងារហេដ្ឋារចនាសម្ព័ន្ធគ្រប់វិស័យក្នុងទូទាំងខេត្ត
- បន្តជំរុញការវិនិយោគក្នុងខេត្ត ទាក់ទាញនូវវិនិយោគិនបន្ថែមទៀត
- បន្តពង្រឹងការងារសន្តិសុខសណ្តាប់ធ្នាប់ សុវត្ថិភាពសាធារណៈ និងជំរុញការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋឱ្យបានកាន់តែល្អប្រសើរ
- ពង្រឹង និងជម្រុញការអនុវត្តគោលនយោបាយភូមិឃុំ សង្កាត់ មានសុវត្ថិភាព
- ជំរុញការងារផលិតកម្មកសិកម្ម ការបង្កបង្កើនផលស្រូវ ឱ្យធានាបាននូវសន្តិសុខស្បៀង និងការនាំចេញ ព្រមទាំងជម្រុញចលនាដាំដុះ ចិញ្ចឹមសត្វ ជាលក្ខណៈសហគមន៍ និងគ្រួសារ
- បន្តការរៀបចំវេទិកាសាធារណៈ នៅគ្រប់ថ្នាក់ ក្រុង ស្រុក និងឃុំ សង្កាត់
- បង្ការបង្ក្រាប និងទប់ស្កាត់បទល្មើសគ្រប់ប្រភេទ សំខាន់ការក្តាប់ជាប់មុខសញ្ញា ជនល្មើស ធ្វើការស្រាវជ្រាវជនល្មើសមិនឱ្យធ្វើសកម្មភាពបាន
- យកចិត្តទុកដាក់ការងារដឹកនាំត្រួតពិនិត្យ និងលុបបំបាត់ការដាក់ប៉ុស្តិ៍ត្រួតពិនិត្យអនាធិបតេយ្យតាមផ្លូវគោក ផ្លូវទឹក
- បន្តអភិវឌ្ឍវិស័យអប់រំ បណ្តុះបណ្តាល កសាងធនធានមនុស្ស និងពង្រឹងសមត្ថភាពមន្ត្រីរាជការ
- បន្តជំរុញការលើកកម្ពស់ការងារសង្គមកិច្ច និងសុខាភិបាល ការផ្សព្វផ្សាយដើម្បីទប់ស្កាត់ជំងឺឆ្លងគ្រប់ប្រភេទ សំខាន់ដូចជាជំងឺផ្តាសាយបក្សី(H5N1) និងប្រភេទថ្មី(H7N9) ជាពិសេសជំងឺកូវីដ-១៩។ល។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែមីនា ឆ្នាំ២០២៣